០០២/១៩-០៩-២០០៧-អវតក-កសចស (អបជ០៣)

C22/I167

# នៅចំពោះមុខអង្គបុរេជំនុំជម្រះ
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

| | |
|---|---|
| សំណុំរឿងលេខ: | ០០២/១៩-០៩-២០០៧-អវតក-កសចស (អបជ០៣) |
| ជូនចំពោះ: | អង្គបុរេជំនុំជម្រះ |
| កាលបរិច្ឆេទឯកសារ: | ២១ កក្កដា ២០០៨ |
| ភាគីដាក់សារណា: | ដើមបណ្ដឹងរដ្ឋប្បវេណីមិនមានមេធាវីបីរូប (សំណុំរឿងលេខ០០១) |
| ភាសាដើម: | អង់គ្លេស |
| ប្រភេទឯកសារ: | សម្ងាត់ |

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 22 / July / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: UCH ARUN

## ការឆ្លើយតបរបស់ដើមបណ្ដឹងរដ្ឋប្បវេណីមិនមានមេធាវីបីរូបទៅនឹងពាក្យសុំពិចារណាឡើងវិញនូវសិទ្ធិរបស់ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងការនិយាយទៅកាន់អង្គជំនុំជម្រះ

**ធ្វើឡើងដោយ**

**ដើមបណ្ដឹងរដ្ឋប្បវេណីមិនមានមេធាវី**

[redacted]

ធ្វើឡើងដោយមានជំនួយពី សារ៉ា ថមម៉ាស
ជំនួយការច្បាប់របស់មជ្ឈមណ្ឌលឯកសារកម្ពុជា
ក្នុងនាមជាការបញ្ចេញយោបល់ផ្ទាល់ខ្លួន

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 21 / 07 / 2008
ម៉ោង (Time/Heure): 16:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. FRY

**ជូនចំពោះ**

**អង្គបុរេជំនុំជម្រះ**

ចៅក្រម ប្រាក់ គឹមសាន
ចៅក្រម រ៉ូ៉ាន់ ដោននីង
ចៅក្រម ណី ថុល
ចៅក្រម កាធិឌកា ឡាហ៊ូ

**សហព្រះរាជអាជ្ញា**

ជា លាង
រ៉ូបឺត ពីទី

**សហមេធាវីរបស់ អៀង សារី**

អាង ឧត្តម
ម៉ៃឃើល កាណាវ៉ា

**សហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី**



Redacted from ERN: 00206472-00206482

## I. សេចក្តីផ្តើម

១ សារណានេះគឺធ្វើឡើងដោយយោងទៅតាម *សេចក្តីណែនាំបន្ថែមរបស់អង្គបុរេជំនុំជម្រះ* ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៨ ដែលបានផ្តល់ឱកាសដល់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿងលេខ០០១ របស់សហចៅក្រមស៊ើបអង្កេត អាចឆ្លើយតបទៅនឹងពាក្យសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណី កញ្ញា សេង ធារី ។ អ្នកធ្វើសារណានេះគឺជាដើមបណ្តឹងរដ្ឋប្បវេណីមួយក្រុមនៅក្នុងសំណុំរឿងលេខ០០១ ដែលមិនទាន់មានមេធាវីតំណាងនៅឡើយ ។ នៅក្នុងការរៀបចំសារណានេះ យើងខ្ញុំទទួលបានជំនួយពី សារ៉ា ថមម៉ាស់ ដែលបញ្ចេញយោបល់ក្នុងនាមផ្ទាល់ខ្លួន ។ ដើម្បីការពារសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី <u>ទាំងអស់</u>ដែលមិនមានមេធាវីតំណាង ដើមបណ្តឹងរដ្ឋប្បវេណីមួយក្រុមនេះសូមស្នើសុំថា អង្គបុរេជំនុំជម្រះទទួលយល់ព្រមតាមពាក្យសុំរបស់ កញ្ញា សេង ធារី ។ ទោះជាយ៉ាងណាក៏ដោយ ដើមបណ្តឹងរដ្ឋប្បវេណីក្រុមនេះស្នើសុំឲ្យអង្គជំនុំជម្រះចាត់វិធានការណ៍ ដើម្បីធានាមិនបង្កភាពយឺតយ៉ាវដល់សវនាការ ។

## II. ព្រឹត្តិការណ៍ដែលពាក់ព័ន្ធ:

២. កាលពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៨ អង្គបុរេជំនុំជម្រះបានច្រានចោលនូវសំណើសុំធ្វើសេចក្តីសន្និដ្ឋានផ្ទាល់មាត់ពីសំណាក់ដើមបណ្តឹងរដ្ឋប្បវេណី កញ្ញា សេង ធារី ។ បន្ទាប់មក កញ្ញា សេង ធារី បានច្រានចោលមេធាវីរបស់ខ្លួនដែលមានឈ្មោះថា ឌី ចាន់ឌី ។ សហមេធាវីអន្តរជាតិរបស់ដើមបណ្តឹងរដ្ឋប្បវេណី សៀលគី ស្លុដហ្វ៊ីងស្គី បានស្នើសុំថា ដើមបណ្តឹង កញ្ញា សេង ធារី ដែលនៅពេលនោះលែងមានមេធាវីតំណាង គួរតែត្រូវអនុញ្ញាតឲ្យធ្វើសេចក្តីសន្និដ្ឋានផ្ទាល់មាត់ដោយខ្លួនឯង ។ អង្គបុរេជំនុំជម្រះបានចេញសេចក្តីសម្រេចផ្ទាល់មាត់មួយច្រានចោលសំណើរបស់ កញ្ញា សេងធារី ដោយបានថ្លែងថា ដើមបណ្តឹងរដ្ឋប្បវេណីមិនអាចនិយាយនៅក្នុងសវនាររបស់អង្គបុរេជំនុំជម្រះទេ បើទោះបីជាមានមេធាវីតំណាង ឬមិនមានមេធាវីតំណាងក៏ដោយ ដោយយោងទៅលើវិធានផ្ទៃក្នុង៧៧(១០) ។ នៅក្នុងយោបល់ជំទាស់នឹងសេចក្តីសម្រេចនេះ លោកចៅក្រមវ៉ាន់ ដោនទីង បានទទួលស្គាល់អំពីភាពមិនស្របគ្នារវាងវិធានផ្ទៃក្នុង វិធាន២៣ និងវិធាន៧៧(១០) និងបានសម្តែងការយល់ឃើញថា "វាមិនមែនជារឿងត្រឹមត្រូវទេ ... ដែលមិនអនុញ្ញាតឲ្យដើមបណ្តឹងរដ្ឋប្បវេណីនេះនិយាយនៅក្នុងតុលាការ" ។

៣. កាលពីថ្ងៃទី២ ខែកក្កដា ឆ្នាំ២០០៨ កញ្ញា សេង ធារី បានដាក់ពាក្យសុំមួយទៅកាន់អង្គបុរេជំនុំជម្រះ ស្នើសុំឲ្យពិចារណាឡើងវិញនូវសិទ្ធិរបស់ខ្លួនក្នុងការនិយាយនៅក្នុងតុលាការដោយផ្ទាល់ ។ កញ្ញា សេង ធារី បានដាក់ពាក្យរួចរាល់កាលពីថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០០៨ ។

៤. នៅថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០០៨ អង្គបុរេជំនុំជម្រះបានចេញសេចក្តីណែនាំថា ភាគី ដែលរួម

ទាំងដើមបណ្តឹងរដ្ឋប្បវេណីផ្សេងទៀតនៅក្នុងសំណុំរឿង០០២ អាចធ្វើការឆ្លើយតបទៅនឹងពាក្យស្នើសុំនេះ និង បានណែនាំថា ពាក្យសុំនោះ "នៅក្នុងដំណាក់កាលនេះ ត្រូវបានចាត់ទុកថាជាសំណើសុំបើកសវនាការឡើងវិញដើម្បីស្តាប់ដើមបណ្តឹងរដ្ឋប្បវេណី" ។ បន្ទាប់មក នៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៨ អង្គបុរេជំនុំជម្រះបានណែនាំទៀតថា ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង០០១ និងសហមេធាវីរបស់ជនត្រូវចោទផ្សេងទៀត ក៏អាចធ្វើការឆ្លើយតបទៅនឹងពាក្យសុំនេះ ។

## III. ប្រភពច្បាប់ដែលពាក់ព័ន្ធ

### ក. អង្គជំនុំជម្រះវិសាមញ្ញ

៥. វិធានផ្ទៃក្នុងបានចែងនៅក្នុងវិធាន២៣(១)(ក)ថា ដើមបណ្តឹងរដ្ឋប្បវេណីអាចចូលរួមនៅក្នុង"សវនាការ"របស់អង្គជំនុំជម្រះវិសាមញ្ញ និងមិនបានដាក់ការកំហិតច្បាស់លាស់ណាមួយចំពោះប្រភេទនៃសវនាការដែលដើមបណ្តឹងអាចចូលរួមបាននោះទេ ។ កាលពីថ្ងៃទី២០ ខែមិនា ឆ្នាំ២០០៨ អង្គបុរេជំនុំជម្រះបានបកស្រាយវិធាននេះដើម្បីផ្តល់ឲ្យដើមបណ្តឹងរដ្ឋប្បវេណីបានចូលរួមនៅក្នុងសវនាបណ្តឹងជំទាស់នឹងការឃុំខ្លួនបណ្តោះអាសន្ន ដោយរកឃើញថា "ភាសានៅក្នុងវិធានផ្ទៃក្នុង២៣(១)(ក)គឺបានសរសេរច្បាស់លាស់ថា ដើមបណ្តឹងរដ្ឋប្បវេណីអាចចូលរួមនៅគ្រប់សវនាការព្រហ្មទណ្ឌទាំងអស់ ដែលរួមទាំងបណ្តឹងជំទាស់នឹងការឃុំខ្លួនបណ្តោះអាសន្ន..." ។ ដូច្នេះ សិទ្ធិក្នុងការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីរួមមានបញ្ចូលការចូលរួមនៅក្នុងការជំនុំជម្រះលើបណ្តឹងជំទាស់នឹងការឃុំខ្លួនបណ្តោះអាសន្នដែរ ។

៦. នៅក្នុងការអនុញ្ញាតឲ្យមានការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី វិធានផ្ទៃក្នុង២៣(១)(ក) មិនបានតម្រូវមានមេធាវីតំណាងទេនៅក្នុងការចូលរួមនេះ ។ តាមការពិត វិធាន២៣(៧)បានចែងថាមេធាវីតំណាងគឺជាសិទ្ធិ មិនមានជាតម្រូវការខានមិនបាននោះទេ ។ ជាងនេះទៅទៀត វិធាន២៣(៨)បានគាំទ្រការសន្និដ្ឋានថា ជាវិធានទូទៅ ដើមបណ្តឹងរដ្ឋប្បវេណីអាចចូលរួមនៅក្នុងសវនាការដោយពុំចាំបាច់មានមេធាវី ដោយសារវាបានផ្តល់ឲ្យសហចៅក្រមស៊ើបអង្កេត និងអង្គជំនុំជម្រះនូវអំណាចក្នុងការស្នើសុំដើមបណ្តឹងរដ្ឋប្បវេណីដែលមិនមានមេធាវីធ្វើការជ្រើសរើសមេធាវី ឬអំណាចក្នុងការតែងតាំងមេធាវីឲ្យដើមបណ្តឹងរដ្ឋប្បវេណីបែបនោះ ។ ដោយសារតុលាការអាចតែងតាំងមេធាវីសម្រាប់ឲ្យដើមបណ្តឹងរដ្ឋប្បវេណីតែ "នៅពេលផលប្រយោជន៍យុត្តិធម៌តម្រូវ" វិធានផ្ទៃក្នុងនេះបានបង្កប់នូវអត្ថន័យអនុញ្ញាតឲ្យដើមបណ្តឹងរដ្ឋប្បវេណីអាចជ្រើសរើសធ្វើជាអ្នកការពារក្តីដោយខ្លួនឯង ។

៧. បើទោះបីជាវិធានផ្ទៃក្នុងបានចែងថា "អង្គជំនុំជម្រះត្រូវតែស្តាប់ដើមបណ្តឹងរដ្ឋប្បវេណី" នៅក្នុងដំណាក់កាលជំនុំជម្រះដំបូង វិធាន៧៧(១០)បានដាក់កំហិតចំពោះលទ្ធភាពនៃដើមបណ្តឹងរដ្ឋប្បវេណីដែលមិនមានមេធាវីតំណាងក្នុងការធ្វើសេចក្តីសន្និដ្ឋានផ្ទាល់មាត់នៅក្នុងដំណាក់កាលបណ្តឹងជំទាស់បុរេជំនុំ



Redacted from ERN: 00206472-00206482

ជម្រះ ដោយបានចែងថា "សហព្រះរាជអាជ្ញា និងមេធាវីរបស់ភាគីអាចធ្វើសេចក្ដីសន្និដ្ឋានសង្ខេប" ។ តាមការពិត អង្គបុរេជំនុំជម្រះបានណែនាំរួចហើយថា វិធាននេះមិនអនុញ្ញាតឲ្យដើមបណ្ដឹងរដ្ឋប្បវេណីធ្វើសេចក្ដីសន្និដ្ឋានផ្ទាល់មាត់ដោយខ្លួនឯងនៅក្នុងដំណាក់កាលបុរេជំនុំជម្រះទេ។ កាលពីថ្ងៃទី២០ ខែឧសភា ២០០៨ អង្គបុរេជំនុំជម្រះបានណែនាំថា វិធានផ្ទៃក្នុង៧៧(១០)នេះគួរតែ"បកស្រាយថា ដើមបណ្ដឹងរដ្ឋប្បវេណីដែលបានជ្រើសរើសមេធាវីតំណាងឲ្យខ្លួននឹងត្រូវធ្វើសេចក្ដីសន្និដ្ឋានដោយសង្ខេប ....តាមរយៈមេធាវីរបស់ពួកគេ" ។

៨. នៅក្នុងការកំណត់សិទ្ធិធ្វើសេចក្ដីសន្និដ្ឋានសង្ខេបនៅក្នុងសវនាការបណ្ដឹងជំទាស់ដំណាក់កាលបុរេជំនុំជម្រះមកឲ្យត្រឹមតែមេធាវីរបស់ភាគី អ្នកធ្វើសេចក្ដីព្រាងវិធាន៧៧(១០)នេះខកខានមិនបានដោះស្រាយសិទ្ធិចូលរួមដោយផ្ទាល់របស់ដើមបណ្ដឹងរដ្ឋប្បវេណីដែលមិនមានមេធាវីតំណាង ។ ដោយសារវិធានផ្ទៃក្នុងតម្រូវឲ្យការជំនុំជម្រះ"ត្រឹមត្រូវ និងឆ្លើយឆ្លងគ្នា និងដើម្បីថែរក្សាតុល្យភាពរវាងសិទ្ធិភាគីផ្សេងៗ" ដើមបណ្ដឹងរដ្ឋប្បវេណីដែលមិនមានមេធាវីតំណាង ក្នុងនាមជាភាគីនៅក្នុងសវនាការ ត្រូវតែអាចប្រើប្រាស់នូវមុខងារទាំងអស់ដែលផ្ដល់ឲ្យទៅភាគីផ្សេងទៀត ។ អង្គបុរេជំនុំជម្រះបានបង្កប់ន័យទទួលស្គាល់លទ្ធភាពរបស់ភាគីដើមបណ្ដឹងរដ្ឋប្បវេណីមិនមានមេធាវីតំណាងឲ្យចូលរួមដោយផ្ទាល់ដោយ-កំណត់ការណែនាំថា "ការសន្និដ្ឋានផ្ទាល់មាត់....ត្រូវតែធ្វើឡើងដោយមេធាវី" តែចំពោះដើមបណ្ដឹងរដ្ឋ-ប្បវេណី"ដែលបានជ្រើសរើសឲ្យមេធាវីតំណាង" ។

## ខ. ច្បាប់កម្ពុជា និងច្បាប់បារាំង

៩. ដូចវិធានផ្ទៃក្នុងដែរ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាបានអនុញ្ញាតឲ្យដើមបណ្ដឹងរដ្ឋប្បវេណីចូលរួមនៅក្នុងសវនាការ និង អនុញ្ញាតឲ្យដើមបណ្ដឹងរដ្ឋប្បវេណីចូលរួមដោយមាន ឬមិនមានមេធាវីតំណាង ។ ដោយសារវិធានផ្ទៃក្នុងគឺជាការរួមបញ្ចូលគ្នា"នីតិវិធីកម្ពុជាដែលមាន" ច្បាប់ក្នុងស្រុកផ្ដល់ការណែនាំដែលជាប្រភពនៃវិធានផ្ទៃក្នុង៧៧(១០) ។ បើទោះបីជា ក្នុងនាមជាវិធានទូទៅ នីតិវិធីត្រូវតែ"ស្របទៅនឹងច្បាប់កម្ពុជា" ប៉ុន្តែតុលាការអាចប្រើប្រាស់បទដ្ឋាននីតិវិធីអន្តរជាតិ ប្រសិនបើ"ច្បាប់កម្ពុជាមិនបានចែងអំពីបញ្ហាជាក់លាក់ណាមួយ ឬ....មានភាពមិនច្បាស់លាស់ចំពោះភាពស្របគ្នារវាងវិធាននោះជាមួយនឹងបទដ្ឋានអន្តរជាតិ..." ។

១០. បទបញ្ញត្តិដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាទាក់ទងនឹងការធ្វើសេចក្ដីសន្និដ្ឋានផ្ទាល់មាត់ដោយដើមបណ្ដឹងរដ្ឋប្បវេណី ភាគច្រើនស្របគ្នាទៅនឹងបញ្ញត្តិដែលមានចែងនៅក្នុងវិធានផ្ទៃក្នុង ។ នៅក្នុងការរៀបរាប់នីតិវិធីក្នុងដំណាក់កាលបុរេជំនុំជម្រះ មាត្រា២៦០(២) បានចែងដោយប្រើពាក្យសម្ដីដូចគ្នាទៅនឹងវិធានផ្ទៃក្នុង៧៧(១០) ចំពោះការសន្និដ្ឋានផ្ទាល់មាត់ដែលត្រូវតែធ្វើឡើងដោយមេធាវី ។ ផ្ទុយទៅវិញ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាបានចែងយ៉ាងច្បាស់ចំពោះសេចក្ដីសន្និដ្ឋានផ្ទាល់មាត់ដោយភាគី



Redacted from ERN: 00206472-00206482

ដើមបណ្ដឹងរដ្ឋប្បវេណីដែលមានមេធាវីតំណាងនៅក្នុងដំណាក់កាលជំនុំជម្រះដំបូង ដោយបន្ថែមនូវអត្ថន័យថា អ្នកធ្វើសេចក្ដីព្រាងច្បាប់នេះមានបំណងមិនអនុញ្ញាតឲ្យភាគីដើមបណ្ដឹងរដ្ឋប្បវេណីដែលមានអ្នកតំណាងធ្វើសេចក្ដីសន្និដ្ឋានផ្ទាល់មាត់នៅក្នុងដំណាក់កាលបុរេជំនុំជម្រះ ។ ដូចវិធានផ្ទៃក្នុងដែរ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាខកខានមិនបានដោះស្រាយចន្លោះប្រហោងទាក់ទងទៅនឹងដើមបណ្ដឹងរដ្ឋប្បវេណីដែលមិនមានមេធាវីតំណាងទេ ។

១១. ដោយសារតែច្បាប់នីតិវិធីកម្ពុជាមានមូលដ្ឋាននៅលើច្បាប់នីតិវិធីបារាំង វាមានភាពស្រដៀងគ្នាជាច្រើនរវាងបញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌបារាំង និងបញ្ញត្តិនៃវិធានផ្ទៃក្នុង និងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ។ ទីមួយ ក្រមនីតិវិធីព្រហ្មទណ្ឌបារាំងមិនតម្រូវឲ្យដើមបណ្ដឹងរដ្ឋប្បវេណីត្រូវតែមានមេធាវីបើទោះបីជាដើមបណ្ដឹងរដ្ឋប្បវេណីនោះ "មានសិទ្ធិទទួលបានជំនួយពីមេធាវីដែលជ្រើសរើសដោយខ្លួនឯងក៏ដោយ...." ។ ទីពីរ ក្រមនីតិវិធីព្រហ្មទណ្ឌបារាំងបានចែងថា នៅក្នុងដំណាក់កាលសវនាការជំទាស់លើការឃុំឃាំងខ្លួនបណ្ដោះអាសន្ន "...មហាអយ្យការ និង មេធាវីរបស់ភាគី...ធ្វើសេចក្ដីសន្និដ្ឋានដោយសង្ខេប" ។ ទីបី ក្រមនីតិវិធីព្រហ្មទណ្ឌបារាំងខកខានមិនបានចែងអំពីការចូលរួមដោយផ្ទាល់របស់ដើមបណ្ដឹងរដ្ឋប្បវេណីមិនមានមេធាវី នៅក្នុងបណ្ដឹងជំទាស់ទាំងបែបនោះ ។

*គ. បទដ្ឋានអន្តរជាតិ*

១២. បញ្ញត្តិដែលមានចែងនៅក្នុងសេចក្ដីសម្រេចចិត្តពីររបស់មហាសន្និបាតសហប្រជាជាតិបានផ្ដល់ការណែនាំទាក់ទងទៅនឹងបទដ្ឋានអន្តរជាតិចាំបាច់ចំពោះការចូលរួមជនរងគ្រោះនៅក្នុងកម្រិតអន្តរជាតិ ។ សេចក្ដីប្រកាសអំពីគោលការណ៍មូលដ្ឋាននៃយុត្តិធម៌សម្រាប់ជនរងគ្រោះនៃឧក្រិដ្ឋកម្ម និងការប្រើប្រាស់អំណាចមិនត្រឹមត្រូវ (The Declaration of Basic Principles of Justice for Victims of Crime and Abuse of Power) បានចែងថា ដើម្បីសម្រេចបានយុត្តិធម៌ រដ្ឋត្រូវតែ "អនុញ្ញាតឲ្យជនរងគ្រោះសម្ដែងយោបល់ និងការព្រួយបារម្ភ និងពិចារណាលើយោបល់ និងការព្រួយបារម្ភទាំងនេះ...នៅក្នុងការជំនុំជម្រះ...[យុត្តិធម៌]" ។ គោលការណ៍មូលដ្ឋាន និងការណែនាំស្ដីអំពីសិទ្ធិទទួលបានដំណោះស្រាយ និងសំណងជម្ងឺចិត្ត (The Basic Principles and Guidelines on the Right to a Remedy and Reparation) បានតម្រូវឲ្យរដ្ឋ "ផ្ដល់ដល់អ្នកដែលអះអាងថាជាជនរងគ្រោះនៃអំពើរំលោភសិទ្ធិមនុស្ស ឬច្បាប់មនុស្សធម៌ នូវសិទ្ធិស្មើភាព និងមានប្រសិទ្ធិភាពក្នុងការទទួលបានយុត្តិធម៌" ។

## IV. អំណះអំណាង

*ក. ដើមបណ្ដឹងរដ្ឋប្បវេណីដែលមានមេធាវីត្រូវតែធ្វើសេចក្ដីសន្និដ្ឋានផ្ទាល់មាត់តាមរយៈមេធាវីតំណាងនៅក្នុងបណ្ដឹងជំទាស់បុរេជំនុំជម្រះ*

១៣. ដោយយោងទៅលើការដែលថា បញ្ញត្តិច្បាស់លាស់នោះគឺធ្វើឡើងសម្រាប់ការចូលរួមដោយ

ផ្ទាល់នៅក្នុងដំណាក់កាលជំនុំជម្រះដំបូង អវត្តមាននៅក្នុងវិធានផ្ទៃក្នុង៧៧(១០)នូវបញ្ញត្តិបែបនោះនៅក្នុងបណ្តឹងជំទាស់បុរេជំនុំជម្រះបានចង្អុលបង្ហាញថា អ្នកធ្វើពង្រៀងច្បាប់នោះមានបំណងមិនអនុញ្ញាតឲ្យដើមបណ្តឹងរដ្ឋប្បវេណីដែលមានមេធាវីធ្វើសេចក្តីសន្និដ្ឋានផ្ទាល់មាត់ដោយផ្ទាល់ទេ ។ យ៉ាងហោចណាស់ក៏ពីរលើករួចមកហើយដែរ អង្គបុរេជំនុំជម្រះបានបញ្ជាក់ថា ដើមបណ្តឹងរដ្ឋប្បវេណីមិនអាចនិយាយដោយផ្ទាល់នៅក្នុងបណ្តឹងជំទាស់បុរេជំនុំជម្រះ ។ អង្គបុរេជំនុំជម្រះអាចបកស្រាយវិធានផ្ទៃក្នុងថាជារឿងត្រឹមត្រូវ ប្រសិនបើការបកស្រាយបែបនោះមិនបំពានសិទ្ធិរបស់ភាគីផ្សេងទៀត ។ ដូច្នេះ យើងសូមលើកឡើងថា អង្គបុរេជំនុំជម្រះធ្វើត្រឹមត្រូវក្នុងការប្រានចោលសំណើររបស់កញ្ញា សេង ធារី សុំនិយាយដោយផ្ទាល់ក្នុងនាមជាភាគីដើមបណ្តឹងរដ្ឋប្បវេណីដែលមានមេធាវីតំណាង ។

១៤. ដោយគម្រូវថា មានតែមេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណីប៉ុណ្ណោះដែលអាចធ្វើសេចក្តីសន្និដ្ឋានផ្ទាល់មាត់បាន អង្គបុរេជំនុំជម្រះបានលើកកំពស់ដំណើរការដ៏មានប្រសិទ្ធិភាពរបស់សវនាការ "នៅក្នុងរយៈពេលសមរម្យ" ដូចដែលមានចែងនៅក្នុងវិធានផ្ទៃក្នុង ។ ដូចដែលអង្គបុរេជំនុំជម្រះបានទទួលស្គាល់ចំនួនដើមបណ្តឹងរដ្ឋប្បវេណីបានកើនឡើង ។ សហមេធាវីរបស់ជនត្រូវចោទខ្លះបានព្រមានថា ការចូលរួមដោយជនរងគ្រោះក្នុងចំនួនច្រើនអាចពន្យាពេលសវនាការជាច្រើន ដែលការណ៍នេះជាការរំលោភលើសិទ្ធិទទួលបានការជំនុំជម្រះដោយមិនពន្យាពេលរបស់ជនត្រូវចោទ ។ ប្រសិនបើការយល់ឃើញ និងការព្រួយបារម្ភរបស់ពួកគេត្រូវបាននិយាយជំនួសដោយមេធាវី ការកំហិតបែបនេះចំពោះលទ្ធភាពចូលរួមដោយផ្ទាល់របស់ដើមបណ្តឹងរដ្ឋប្បវេណីដែលមានមេធាវី គឺជារឿងសមរម្យ ។ ដើម្បីឲ្យមានប្រសិទ្ធិភាពនៃការជំនុំជម្រះ ដើមបណ្តឹងរដ្ឋប្បវេណីដែលមានមេធាវីតំណាងគួរតែមិនអាចចៀសវៀងពីវិធានផ្ទៃក្នុង៧៧(១០) ដោយរក្សាសិទ្ធិនិយាយដូចដែលកញ្ញា សេង ធារី ប៉ុនប៉ងធ្វើនោះទេ ។

១៥. ផ្ទុយទៅនឹងការជំទាស់របស់ កញ្ញា សេង ធារី ជនរងគ្រោះមិនមាន "សិទ្ធិជាសារវន្ត" ក្នុងការនិយាយដោយផ្ទាល់ខ្លួននោះទេ ។ ផ្ទុយទៅវិញ បទដ្ឋានអន្តរជាតិបានចែងថា ជនរងគ្រោះមានសិទ្ធិបញ្ចេញ "ការយល់ឃើញ និងការព្រួយបារម្ភ..." ។ អង្គបុរេជំនុំជម្រះបានរកឃើញថា ដើមបណ្តឹងរដ្ឋប្បវេណីមាន "សិទ្ធិ...ក្នុងការចូលរួមរបៀបលាយល័ក្ខអក្សរ និងផ្ទាល់មាត់នៅក្នុងសវនាការ..." ។ ដោយសារតែមេធាវីតំណាងអាចបញ្ចេញនូវការយល់ឃើញ ឬការព្រួយបារម្ភទាំងនេះ អង្គបុរេជំនុំជម្រះមិនបានរំលោភសិទ្ធិក្នុងការចូលរួមតាមរបៀបផ្ទាល់មាត់តាមរយៈការហាមប្រាមការចូលរួមដោយផ្ទាល់របស់ដើមបណ្តឹងរដ្ឋប្បវេណីដែលមានមេធាវីតំណាងនៅក្នុងដំណាក់កាលបណ្តឹងជំទាស់បុរេជំនុំជម្រះ ។ ដូចពួកយើងដែរ ដើមបណ្តឹងរដ្ឋប្បវេណីភាគច្រើនទំនងជាចង់បានមេធាវីនិយាយជំនួសពួកខ្លួន ។ ដូច្នេះ ផ្ទុយទៅនឹងការព្រមានរបស់សហមេធាវីអន្តរជាតិរបស់ដើមបណ្តឹងរដ្ឋប្បវេណី ការដាក់កំហិតនេះមិនទំនងជាជម្រុញឲ្យដើមបណ្តឹងរដ្ឋប្បវេណីជាច្រើនប្រានចោលមេធាវីរបស់ខ្លួនដើម្បីបាននិយាយដោយខ្លួនឯងនោះ



Redacted from ERN: 00206472-00206482

ខ។

១. ដើមបណ្ដឹងរដ្ឋប្បវេណីមិនមានមេធាវីមានសិទ្ធិធ្វើសេចក្ដីសន្និដ្ឋានផ្ទាល់មាត់ដោយផ្ទាល់នៅក្នុងបណ្ដឹងជំទាស់បុរេជំនុំជម្រះ

១៦. ដូចដែលអង្គបុរេជំនុំជម្រះបានរកឃើញរួចហើយ "ដើមបណ្ដឹងរដ្ឋប្បវេណីមានសិទ្ធិសកម្មក្នុងការចូលរួមចាប់តាំងពីដំណាក់កាលស៊ើបអង្កេតនៃនីតិវិធី"។ សេចក្ដីសន្និដ្ឋានផ្ទាល់មាត់គឺជាផ្នែកមួយយ៉ាងសំខាន់នៃការចូលរួមនេះ។ ដូច្នេះ ប្រសិនបើចង់ឲ្យសិទ្ធិចូលរួមនេះមានអត្ថន័យ ដើមបណ្ដឹងរដ្ឋប្បវេណីមិនមានមេធាវី(ដូចដែលអនុញ្ញាតដោយវិធានផ្ទៃក្នុង) ត្រូវតែអាចធ្វើសេចក្ដីសន្និដ្ឋានផ្ទាល់មាត់ដោយផ្ទាល់ទៅកាន់តុលាការ។ ដោយសារតែពួកគេខ្វះមេធាវីធ្វើសេចក្ដីសន្និដ្ឋានផ្ទាល់មាត់ជំនួសឲ្យពួកគេ នេះគឺជាការសន្និដ្ឋានយ៉ាងឡូហ្សិកចំពោះការអនុញ្ញាតឲ្យដើមបណ្ដឹងរដ្ឋប្បវេណីចូលរួមដោយគ្មានមេធាវី។ នៅក្នុងសេចក្ដីណែនាំចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០០៨ អង្គបុរេជំនុំជម្រះបានយល់ឃើញដូចគ្នានៅពេលធ្វើការបកស្រាយទៅកាន់មេធាវីភាគីអំពីព្រំដែនកំហិតនៃវិធាន៧៧(១០)នៃការធ្វើការសន្និដ្ឋានផ្ទាល់មាត់ថា មិនអនុញ្ញាតតែដើមបណ្ដឹងរដ្ឋប្បវេណីមានមេធាវីប៉ុណ្ណោះក្នុងការនិយាយផ្ទាល់មាត់។

១៧. អង្គបុរេជំនុំជម្រះមិនគួរពិចារណាការខកខានរបស់វិធាន៧៧(១០)មិនបានចែងអំពីការធ្វើសេចក្ដីសន្និដ្ឋានផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណីមិនមានមេធាវី ថាមិនអាចដោះស្រាយបាននោះទេ។ វិធានផ្ទៃក្នុងមានភាពខ្វះចន្លោះជាច្រើន។ វិធាន៧៧(១០)ត្រូវបានយកចេញដោយផ្ទាល់ពីក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ហើយក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាយកចេញពីក្រមនីតិវិធីព្រហ្មទណ្ឌបារាំង ដោយមិនមានធ្វើវិសោធនកម្ម ដែលបណ្ដាលឲ្យមានការខ្វះចន្លោះចែងអំពីការចូលរួមដោយផ្ទាល់របស់ដើមបណ្ដឹងរដ្ឋប្បវេណីដែលមិនមានមេធាវី។ នៅក្នុងករណីដែលមានការខ្វះចន្លោះ តុលាការត្រូវតែសម្រេចដោយស្របទៅតាមគោលការណ៍ជាសារវន្តរបស់វិធានផ្ទៃក្នុង និងបទដ្ឋានអន្តរជាតិ។ តាមរយៈការផ្ដល់ទៅឲ្យដើមបណ្ដឹងរដ្ឋប្បវេណីមិនមានមេធាវីនូវសិទ្ធិតិចតួចជាង វិធាន៧៧(១០)គឺមិនសមស្របទៅនឹងទាំងគោលការណ៍ជាសារវន្ត និងបទដ្ឋានអន្តរជាតិ ដែលតម្រូវថា "ត្រូវតែរក្សាឲ្យមានតុល្យភាពរវាងសិទ្ធិរបស់ភាគី" និងថា ជនរងគ្រោះមានសិទ្ធិស្មើភាពគ្នាក្នុងការទទួលបានយុត្តិធម៌។

១៨. សេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះកាលពីថ្ងៃទី២ ខែកក្កដា បានបង្កើតជាយុត្តិសាស្ត្រដ៏គួរឲ្យព្រួយបារម្ភមួយចំពោះការចូលរួមរបស់ដើមបណ្ដឹងរដ្ឋប្បវេណីដែលមិនមានមេធាវី ដោយសារតែសេចក្ដីសម្រេចនេះបានរាំងភាគីរដ្ឋប្បវេណីមិនមានមេធាវី មិនឲ្យបញ្ចេញនូវការយល់ឃើញ និងការព្រួយបារម្ភនៅក្នុងដំណាក់កាលបុរេជំនុំជម្រះ។ ដូចដែលបានលើកឡើងដោយចៅក្រម ប្រ៉ាន់ដោននីង វាជារឿងមិនត្រឹមត្រូវទេដែលមិនអនុញ្ញាតឲ្យ កញ្ញា សេង ធារី និង ប្រហែលជាអាចដើមបណ្ដឹងរដ្ឋប្បវេណីមិនមានមេធាវីផ្សេងទៀត ក្នុងការនិយាយទៅកាន់តុលាការ។ តាមរយៈការផ្ដល់



Redacted from ERN: 00206472-00206482

ឲ្យយើងខ្ញុំនូវសិទ្ធិតិចតួចជាង អង្គបុរេជំនុំជម្រះហាក់បីដូចជាបានដាក់កំហិតមកលើដើមបណ្តឹងរដ្ឋប្បវេណី ដូចជាយើងខ្ញុំដោយសារតែយើងខ្ញុំមិនមានមេធាវី បើទោះបីជាវិធានផ្ទៃក្នុងមិនតម្រូវឲ្យធ្វើដូច្នេះក៏ដោយ ។ គោលជំហររបស់អង្គបុរេជំនុំជម្រះគឺមិនសមរម្យទេ ដោយសារមានដើមបណ្តឹងរដ្ឋប្បវេណីជាច្រើន ដូចជាយើងខ្ញុំដែរ មិនមែនពុំព្រមយកមេធាវីនោះទេ ។ អង្គជំនុំជម្រះវិសាមញ្ញមិនបានផ្តល់ថវិកាឲ្យទៅមេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណី ហើយមេធាវីមានបទពិសោធន៍ខ្ពស់តិចណាស់ដែលស្ម័គ្រចិត្តធ្វើការដោយមិនយកកម្រៃ ។

១៩ ការអានដ៏ត្រឹមត្រូវរបស់វិធានផ្ទៃក្នុងគឺវាបានផ្តល់សិទ្ធិដូចគ្នាទៅឲ្យគ្រប់ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ ដោយមិនគិតថាមានមេធាវី ឬមិនមានមេធាវីនោះទេ ។ មកទល់ពេលនេះ បើទោះបីជាការធ្វើសេចក្តីសន្និដ្ឋានផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណីប្រហែលអាចអូសបន្លាយសវនាការខ្លះមែន ប៉ុន្តែ អង្គបុរេជំនុំជម្រះគួរតែដោះស្រាយបញ្ហានេះដោយគ្រប់គ្រងសវនាការឲ្យមានប្រសិទ្ធិភាព ជាជាងការហាមឃាត់ទាំងស្រុងចំពោះការធ្វើសេចក្តីសន្និដ្ឋានបែបនោះ ។ ដោយសារតែពួកយើងខ្ញុំមិនទាន់មានមេធាវីការពារ យើងខ្ញុំសូមរំលឹកអង្គបុរេជំនុំជម្រះថា សិទ្ធិរបស់យើងទទួលរងនូវការប៉ះពាល់យ៉ាងខ្លាំងបើប្រៀបធៀបទៅនឹងសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលមានមេធាវីតំណាង ប្រសិនបើអង្គបុរេជំនុំជម្រះមិនពិចារណាឡើងវិញនូវសេចក្តីសម្រេចកាលពីថ្ងៃទី២ ខែកក្កដា ទេ ។ យើងខ្ញុំសូមស្នើសុំឲ្យអង្គបុរេជំនុំជម្រះទទួលយល់ព្រមតាមសំណើររបស់ កញ្ញា សេង ធារី និង បើសវនាការឡើងវិញ ដើម្បីឲ្យ កញ្ញា សេង ធារី អាចនិយាយបាននៅក្នុងសវនាការ ។ ប្រសិនបើសម្រេចបើសវនាការឡើងវិញ យើងសូមស្នើសុំថា អង្គបុរេជំនុំជម្រះពិចារណាវិធានការណ៍ដូចខាងក្រោមដើម្បីធានាឲ្យបាននូវដំណើរការជំនុំជម្រះយ៉ាងរលូន ។

*គ. អង្គជំនុំជម្រះគួរតែប្រកាន់យកវិធីដោះស្រាយបញ្ហាដែលមានស្រាប់ចំពោះការបែងចែកពេលវេលាសម្រាប់ការផ្តល់ទស្សីករណ៍ផ្ទាល់មាត់ដើម្បីធានាឲ្យមានភាពសមស្រប ក្នុងដំណើរការនីតិវិធី*

២០ វាជាភាពសមស្របមួយនិងសេចក្តីប្រាថ្នាចង់បានរបស់អង្គបុរេជំនុំជម្រះក្នុងការប្រកាន់យកវិធីដោះស្រាយបញ្ហាដែលមានស្រាប់ចំពោះបទបញ្ញត្តិឲ្យដាក់ជូនទស្សីករណ៍ផ្ទាល់មាត់ពីភាគីដើមបណ្តឹងរដ្ឋប្បវេណីដែលមិនមានតំណាង នៅក្នុងសវនាការដែលបានធ្វើឡើងនេះ ហើយក៏ដូចជានៅក្នុងសវនាការផ្សេងៗទៀតដែរ ។ វិធានផ្ទៃក្នុងបានចែងថា ចៅក្រម "ត្រូវធានារ៉ាប់រងឲ្យមានសណ្តាប់ធ្នាប់ល្អ" ព្រមទាំង "ត្រូវធានាដល់ការអនុវត្តសិទ្ធិការពារខ្លួនឲ្យប្រព្រឹត្តទៅបានដោយសេរី" ដែលរាប់បញ្ចូលទាំងសិទ្ធិ "ទទួលបានការជំនុំជម្រះដោយពុំមានការពន្យាពេល" ។ ការបែងចែកច្បាស់លាស់ស្តីអំពីការដាក់ជូនទស្សីករណ៍ផ្ទាល់មាត់ពីខាងភាគីដើមបណ្តឹងរដ្ឋប្បវេណីស្តែងឲ្យឃើញពីសារសំខាន់យ៉ាងខ្លាំងខណៈពេល-



Redacted from ERN: 00206472-00206482

ដែលចំនួនភាគីដើមបណ្តឹងរដ្ឋប្បវេណីបានកើនឡើង ដូចបានកំណត់ចំណាំដោយអង្គបុរេជំនុំជម្រះវិសាមញ្ញ ហើយនិងបន្តកើនឡើងដោយសារតែដើមបណ្តឹងរដ្ឋប្បវេណីបានចូលរួមនៅក្នុងដំណើការនិតិវិធី ។ ដោយសារតែជាទូទៅអង្គបុរេជំនុំជម្រះវិសាមញ្ញមានការខ្វះខាតខាងការបណ្តុះបណ្តាលផ្នែកច្បាប់ អង្គជំនុំបុរេជម្រះគួរតែបានបែងចែកការដាក់ជូនទឡ្ហីករណ៍ផ្ទាល់មាត់ពីខាងភាគីដើមបណ្តឹងរដ្ឋប្បវេណីដែលមិនមានតំណាង ឲ្យកាន់តែក្បៀក្បាឡើង ។

២១. ដើម្បីធានាឲ្យការប្រព្រឹត្តទៅបានឆាប់រហ័សនៃដំណើការនីតិវិធី អង្គបុរេជំនុំជម្រះគួរតែ ក. បន្តកំណត់ពេលវេលាដែលបានបែងចែកសម្រាប់ការជូនទឡ្ហីករណ៍ផ្ទាល់មាត់ពីខាងភាគីដើមបណ្តឹងរដ្ឋប្បវេ-ណី ខ. តម្រូវឲ្យភាគីដើមបណ្តឹងរដ្ឋប្បវេណីនិយាយតែទៅលើបញ្ហាច្បាស់លាស់ដែលកំពង់នៅក្នុងការពិនិត្យពិចារណា និង គ. ទប់ស្កាត់ភាគីដើមបណ្តឹងរដ្ឋប្បវេណីកុំឲ្យនិយាយច្រំដែលលើទឡ្ហីករណ៍ដែលបានលើកឡើងរួចហើយដោយភាគីផ្សេងៗទៀត ។ ក្នុងន័យនេះ ប្រធានអង្គជំនុំបុរេជម្រះមានអំណាចក្នុងការ "បដិសេធនូវរាល់នីតិវិធីដែលនាំឲ្យមានការពន្យាពេលដល់ការជំនុំជម្រះ និងដែលមិនអាចនាំទៅដល់ការស្វែងរកការពិត" ។ ចៅក្រមគួរតែប្រើអំណាចនេះដើម្បីទប់ស្កាត់នូវរាល់ការដាក់ជូនទឡ្ហីករណ៍ណាដែលមិនពាក់ព័ន្ធឬច្រំដែលពីសំណាក់ភាគីដើមបណ្តឹងរដ្ឋប្បវេណីក្នុងអំឡុងពេលមានស-វនាការ ជាជាងទាត់ចោលទឡ្ហីករណ៍បែបនេះ ដោយសារតែទឡ្ហីករណ៍នោះបានលើកឡើងរួចហើយ ។

២២. នៅពេលដែលវិធានការណ៍ទាំងនេះមិនមានប្រសិទ្ធិភាពដើម្បីធានាឲ្យការប្រព្រឹត្តទៅនៃដំណើការជំនុំជម្រះបានឆាប់រហ័សទេនោះ អង្គបុរេជំនុំជម្រះគួរតែរៀបចំឲ្យមានតំណាងជាក្រុមឲ្យភាគីដើមបណ្តឹងរដ្ឋប្បវេណី ។ ឧទាហរណ៍ នៅពេលដែលភាគីដើមបណ្តឹងរដ្ឋប្បវេណីដែលមិនមានតំណាងខ្វះជំនាញផ្នែកច្បាប់ក្នុងការរួមចំនែកប្រកបដោយខ្លឹមសារនោះ ឬខកខានមិនបានអនុវត្តន៍តាមនីតិវិធី ឬសណ្តាប់ធ្នាប់របស់អង្គបុរេនោះ អង្គបុរេអាចស្នើរសុំឲ្យភាគីដើមបណ្តឹងរដ្ឋប្បវេណីជ្រើសរើសមេធាវីណាម្នាក់ក្នុងពេលវេលាកំណត់មួយ ។ ប្រសិនបើភាគីដើមបណ្តឹងរដ្ឋប្បវេណីខកខានមិនធ្វើតាមហើយ "នៅពេលដែលផលប្រយោជន៍យុត្តិធម៌ទាមទារ" អង្គបុរេមានអំណាចតែងតាំងមេធាវីឲ្យភាគីដើមបណ្តឹងរដ្ឋប្បវេណី ។ ក្នុងករណីមានភាគីដើមបណ្តឹងរដ្ឋប្បវេណីច្រើន អង្គបុរេអាចយល់ថា ខ្លួនមានអំណាចដើម្បីតម្រូវឲ្យបុគ្គលដើមបណ្តឹងរដ្ឋប្បវេណីចងជាក្រុមដោយមានតំណាងរួម ចៀសវាងចំនួនទឡ្ហីករណ៍ច្រើនលើសលប់ ។

## V. សេចក្តីសន្និដ្ឋាន

២៣. ក្នុងនាមជាអ្នកឆ្លើយតប យើងស្នើរឡើងថាអង្គបុរេទទួលយល់ព្រមតាមសំណើររបស់ កញ្ញា សេង ធារី ហើយបើកសវនាការសាជាថ្មីម្តងទៀតដើម្បីឲ្យកញ្ញា សេង ធារីឲ្យយល់បានៗ ដោយការប្រានចោលសិទ្ធិចូលរួមផ្ទាល់ពីសំណាក់ ភាគីដើមបណ្តឹងរដ្ឋប្បវេណីដែលមិនមានតំណាងនៅក្នុងបណ្តឹង



Redacted from ERN: 00206472-00206482

ទទួរណ៍របស់អង្គបុរេ សេចក្តីសម្រេចចុះថ្ងៃទី២ ខែកក្កដា បានរំលោភសិទ្ធិបញ្ចេញមតិ និងដាក់ជូនដើម្បីឲ្យពិនិត្យពិចារណាក្នុងអំឡុងពេលមានការជំនុំជម្រះតាមផ្លូវច្បាប់ និងនាំឲ្យមានការទទួលបានយុត្តិធម៌មិនស្មើគ្នាសម្រាប់ជនរងគ្រោះនៃរបបកម្ពុជាប្រជាធិបតេយ្យ ក៏ដូចជាអ្នកទាំងនោះផ្ទាល់ ។

២៨. ដើម្បីធានាឲ្យការប្រព្រឹត្តទៅបានឆាប់រហ័សនៃសវនាការដែលបើកសាជាថ្មីទៀតនោះ យើងស្នើឡើងថា អង្គបុរេបន្តកំណត់ពេលវេលាដែលបានបែងចែកសម្រាប់ការដាក់ជូនទឡ្ហីករណ៍ផ្ទាល់មាត់ពីសំណាក់ភាគីដើមបណ្តឹងរដ្ឋប្បវេណី ទប់ស្កាត់ការជូនទឡ្ហីករណ៍ផ្ទាល់មាត់ដែលមិនពាក់ព័ន្ធឬច្រំដែល ហើយពិចារណាថាតើការតែងតាំងមេធាវីម្នាក់ទៅឲ្យកញ្ញា សេង ធារី នឹងស្ថិត“ក្នុងប្រយោជន៍យុត្តិធម៌” ដែរឬអត់ ។



Redacted from ERN: 00206472-00206482

០០២/១៩-០៩-២០០៧-អវគក-កសចស (អបជ០៣)

C22/I/67

ដោយសារមូលហេតុទាំងនេះ យើងខ្ញុំស្នើសុំថា អង្គបុរេជំនុំជម្រះ៖

យល់ព្រមតាមពាក្យស្នើសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណី កញ្ញា សេង ធារី និងបើកសវនាការឡើងវិញ ដើម្បីអនុញ្ញាតឲ្យ កញ្ញា សេង ធារី ឬ មេធាវីដែលត្រូវបានតែងតាំងតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីនេះ អាចបញ្ចេញសម្លេងនៅក្នុងសវនាការ ។



ស្នាមមេដៃ៖

ឈ្មោះ........[redacted].......................(ដើមបណ្តឹងរដ្ឋប្បវេណី)

កាលបរិច្ឆេទ........ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០៨........

អស័យដ្ឋាន........[redacted]



ស្នាមមេដៃ៖

ឈ្មោះ........[redacted].......................(ដើមបណ្តឹងរដ្ឋប្បវេណី)

កាលបរិច្ឆេទ........ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០៨

អស័យដ្ឋាន........[redacted]



ស្នាមមេដៃ៖

ឈ្មោះ........[redacted].......................(ដើមបណ្តឹងរដ្ឋប្បវេណី)

កាលបរិច្ឆេទ........ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០៨

អស័យដ្ឋាន........[redacted]



Redacted from ERN: 00206472-00206482